របាយការណ៍ស្តីពី

# វគ្គបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សា ស្តីពីការផ្តល់ប្រឹក្សាលើការ ថែទាំ និងព្យាបាលជំងឺឱកាសនិយម និង ការព្យាបាលដោយឱសថ ប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារផ្ទុកមេរោគអេដស៍

## Initial Training for Counselors on Management of Opportunistic Infection and Antiretroviral Therapy for HIV Infected Adults and Children

Frangipani Villa Hotel, from May 01-12, 2017









Prepared by

Supported by

AHF CAMBODIA

# វគ្គបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សា ស្តីពីការផ្តល់ប្រឹក្សាលើការថែទាំ និង ព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារផ្ទុកមេរោគអេដស៍

Initial Training for Counselors on Management of Opportunistic Infection and Antiretroviral Therapy for HIV Infected Adults and Children

១. ទីកន្លែង: នៅសណ្ឋាគារ Frangipani Villa Hotel, រាជធានីភ្នំពេញ

២. កាលបរិច្ឆេទបណ្តុះបណ្តាល: ពីថ្ងៃទី០១ ខែឧសភា ដល់ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៧

៣. រៀបចំដោយ: AIDS Care Unit (NCHADS)

៤. សហការឧបត្ថម្ភថវិកាដោយ: AHF

៥. គោលបំណង:

ផ្តល់ចំណេះដឹងថ្មីៗ ស្តីពីការថែទាំ-ព្យាបាលជំងឺឱកាសនិយម និង ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារ ដល់អ្នកផ្តល់ប្រឹក្សាលើមនុស្សពេញវ័យ និង កុមារដែលកំពុងបំរើការងារ នៅសេវាថែទាំព្យាបាលជំងឺអេដស៍នៅតាមមន្ទីរពេទ្យខេត្ត/មន្ទីរពេទ្យបង្អែកស្រុកនានា។

៦. សមាសភាពនៃអ្នកចូលរួម:

- ជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល:
  លោកវេជ្ជ. ***លី ពេញស៊ុន*** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។
  លោកវេជ្ជ. ***ស្រី វណ្ណធូន*** ប្រធានអង្គការAHF
- អ្នកសំរបសំរួលថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ:
  ១. លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ — ប្រធានផ្នែកថែទាំជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិ
  ២. លោកវេជ្ជ. ង៉ូវ បូរ៉ា — អនុប្រធានផ្នែកថែទាំជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិ
- **NCHADS Organizer:**
  ១. លោកស្រី លី ប៊ុណ្ណារី — មន្ត្រីផ្នែកថែទាំជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិ
- គ្រូបណ្តុះបណ្តាលមកពីមន្ទីរពេទ្យថ្នាក់ជាតិ:
  ១. លោកស្រីវេជ្ជ. គី សុវឌ្ឍនា — គ្រូផ្នែកថែទាំជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិ
  ២. លោកស្រីវេជ្ជ. ខេង ម៉ារេត — គ្រូមកពីមន្ទីរពេទ្យកុមារជាតិ
  ៣. លោកវេជ្ជ. ចាន់ គួង — គ្រូមកពីគ្លីនិកសុខភាពសង្គម
  ៤. លោក ឡេង ចាន់រតនា — គ្រូមកពីមជ្ឈមណ្ឌលជាតិ
- សិក្ខាកាមចូលរួមដែលអញ្ជើញមកពី: មានសរុប ២៦នាក់

*១. ខេត្តកំពង់ចាម*

- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម — ចំនួន ០២ នាក់
- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកជើងព្រៃ — ចំនួន០២នាក់

*២. ខេត្តសៀមរាប*

- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកសៀមរាប ចំនួន ០២ នាក់
- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកសូនិគម ចំនួន ០១ នាក់

*៣. ខេត្តកំពង់ឆ្នាំង*

- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង ចំនួន ០២ នាក់

*៤.ខេត្តឧត្តរមានជ័យ*

- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកសំរោង ចំនួន ០២ នាក់
- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកអន្លង់វែង ចំនួន ០២ នាក់

*៥. ខេត្តបន្ទាយមានជ័យ*

- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកព្រះនេតព្រះ ចំនួន០៤នាក់

*៦. ខេត្តកំពត*

- គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកខេត្តកំពត ចំនួន០២នាក់

គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែកកំពង់ត្រាច ចំនួន០២នាក់

*៧. មន្ទីរពេទ្យរាជធានីភ្នំពេញ:*

- គ្រូពេទ្យមកពីគ្លីនិកសុខភាពសង្គម ចំនួន០៣នាក់

*៨.អង្គការ:*

- គ្រូពេទ្យមកពីអង្គការ FHI360 កំពង់ចាម ចំនួន ០២ នាក់

**ប្រធានបទដែលយកមកបង្រៀនក្នុងវគ្គបណ្តុះបណ្តាលសំរាប់រយៈពេល ១០ ថ្ងៃ នេះរួមមានដូចក្នុងតារាងខាងក្រោម៖**

| Module No. | Time | Topic | Resource Person |
|---|---|---|---|
| | *Day 1 ថ្ងៃទី០១ ខែ ឧសភា ឆ្នាំ ២០១៧* | | |
| | 8.00 a.m.to 9.00 a.m. | ការចុះវត្តមាន | NCHADS Team |
| | 9.00 a.m. to 9.30 a.m. | ពិធីបើកវគ្គក្រោមអធិបតី:<br>• មតិស្វាគមន៍និងសំណេះសំណាលរបស់លោក ប្រធានអង្គការAHF.<br>• មតិស្វាគមន៍ និងការប្រកាសបើកវគ្គរបស់លោកប្រធានមជ្ឈមណ្ឌលជាតិ (NCHADS). | NCHADS Team |
| | *9.30 a.m. to 9.45 a.m.* | *Tea Break* | |
| | 9.45 a.m. to 11.45 a.m. | តេស្តមុនវគ្គបណ្តុះបណ្តាល<br>ការណែនាំអោយស្គាល់គ្នា | NCHADS Team |
| | 11.45 p.m. to 2.00 p.m. | Lunch break | |
| 2 | 2.00 p.m. to 3.15 p.m. | Introduction to CoC | Dr. Sovathana<br>Dr. Sovannarith |
| | *3.15 p.m. to 3.30 p.m.* | *Tea Break* | |

| | | | |
|---|---|---|---|
| | 3.30 p.m. to 5.00 p.m. | Introduction to CoC (Continue)<br>ព័ត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍ | Dr. Sovathana<br>Dr. Kheng Mareth |
| Day 2: ថ្ងៃទី០២ ខែ ឧសភា ឆ្នាំ ២០១៧ | | | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី១ | NCHADS Team |
| 1 | 8.30 a.m. to 9.45 a.m. | ព័ត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជម្ងឺ អេដស៍ (បន្ត) | Dr. Kheng Mareth |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| 12 | 10.00 a.m. to 12.00 p.m. | ការការពារការចម្លងមេរោគអេដស៍ក្រោយពេលផ្ទុក | Dr. Chan Koung |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 3 | 2.00 p.m. to 3.30 p.m. | ការផ្តល់ប្រឹក្សាជាមូលដ្ឋានទាក់ទងមេរោគអេដស៍នឹងជម្ងឺអេដស៍ | Dr. Kheng Mareth |
| | 3.30 p.m. to 3.45 p.m. | Tea Break | |
| | 3.45 p.m. to 4.45 p.m. | ការផ្តល់ប្រឹក្សាជាមូលដ្ឋានទាក់ទងមេរោគអេដស៍នឹងជម្ងឺអេដស៍ (បន្ត) | Dr. Kheng Mareth |
| | 4.45 p.m. to 5.00 p.m. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| Day-3: ថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ២០១៧ | | | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី២ | NCHADS Team |
| 7 | 8.30 a.m. to 9.45 a.m. | ការយល់ដឹងពីដំណាក់ការវិវឌ្ឍន៍របស់កុមារ និង យុវវ័យ | Dr. Sovathana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| 22 | 10.00 a.m. to12.00 p.m. | អ្នកថែទាំតាមផ្ទះ | Mr. Chanrattana |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 4 | 2.00 p.m. to 3.30 p.m. | តម្លៃនឹងអាកប្បកិរិយារបស់អ្នកផ្តល់ប្រឹក្សា | Dr. Chan Koung |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |
| 18 | 3.45 p.m. to 4.45 p.m. | ការយកចិត្តទុកដាក់ថែទាំចំពោះអ្នកផ្តល់សេវា | Dr. Kheng Mareth |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| Day-4: ថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ ២០១៧ | | | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី៣ | NCHADS Team |
| 5 | 8.30 a.m. to 9.45 a.m. | ជំនាញក្នុងការធ្វើទំនាក់ទំនង | Dr. Sovathana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| | 10.00 a.m. to 12.00 p.m. | ជំនាញក្នុងការធ្វើទំនាក់ទំនង (Continue) | Dr. Sovathana |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 9 | 2.00 p.m. to 3.30 p.m. | ស្វែងយល់អំពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | Mr. Chanrattana |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |
| | 3.45 p.m. to 4.45 p.m. | ស្វែងយល់អំពីការព្យាបាលដោយឱសថប្រឆាំង | Mr. Chanrattana |

| | | | |
|---|---|---|---|
| | | មេរោគអេដស៍ (Continue) | |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| | | *Day -5: ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១៧* | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី៤ | NCHADS Team |
| 11 | 8.30 a.m. to 9.45 a.m. | ការផ្តល់ប្រឹក្សាសម្រាប់បង្ការការចម្លងមេរោគអេសដ៏ពីម្តាយទៅកូន (PMTCT) | Dr. Sovathana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| 24 | 10.00 a.m. to 12.00 p.m. | ការពន្យាកំណើត | Dr. Sovathana |
| | 12.00 p.m. to 2.00 p.m. | Lunch break | |
| 8 | 2.00 p.m. to 3.30 p.m. | ជំងឺឱកាសនិយមនិងការបង្ការ | Dr. Kheng Mareth |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |
| | 3.45 p.m. to 4.45 p.m. | ជំងឺឱកាសនិយមនិងការបង្ការ (Continue) | Dr. Kheng Mareth |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| | | *Day -6: ថ្ងៃទី០៨ ខែ ឧសភា ឆ្នាំ ២០១៧* | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃ៥ | |
| 10 | 8.30 a.m. to 9.45 a.m. | ការប្រកាន់ខ្ជាប់ខ្លួន (ការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងតាមវេជ្ជបញ្ជា) ក្នុងការព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍ | Dr. Chan Koung |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| | 10.00 a.m. to 12.00 p.m. | ការប្រកាន់ខ្ជាប់ខ្លួន (ការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងតាមវេជ្ជបញ្ជា) ក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (Continue) | Dr. Chan Koung |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 20 | 2.00 p.m. to 3.30 p.m. | អន្តរកាលនៅក្នុងវ័យជំទង់ | Dr. Sovathana |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |
| 15 | 3.45 p.m. to 4.45 p.m. | ភាពអស់កម្លាំងចិត្តកម្លាំងកាយរបស់អ្នកថែទាំ | Dr. Sovathana |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | |
| | | *Day-7: ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០១៧* | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី៦ | NCHADS Team |
| 6 | 8.30 a.m. to 9.45 a.m. | ការផ្លាស់ប្តូរឥរិយាបទ ក្នុងការទំនាក់ទំនង | Mr. Chanrattana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| | 10.00 a.m. to 12.00 p.m. | ការផ្លាស់ប្តូរឥរិយាបទ ក្នុងការទំនាក់ទំនង (Continue) | Mr. Chanrattana |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 14 | 2.00 p.m. to 3.30 p.m. | ការថែទាំ និងព្យាបាលបន្ថយការឈឺចាប់បណ្តោះអាសន្ន(Adult) | Dr. Sovathana |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |

| | | | |
|---|---|---|---|
| | 3.45 p.m. to 4.45 p.m. | ការថែទាំ និងព្យាបាលបន្ថយការឈឺចាប់បណ្ដោះអាសន្ន(Adult) (Continue) | Dr. Sovathana |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| *Day-8: ថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០១៧* | | | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី៧ | NCHADS Team |
| 13 | 8.30 a.m. to 9.45 a.m. | ការបង្កើបការពិតពីស្ថានភាពមេរោគអេដស៍ ដល់ កុមារ | Mr. Chanrattana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| | 10.00 a.m. to 12.00 p.m. | ការបង្កើបការពិតពីស្ថានភាពមេរោគអេដស៍ ដល់ កុមារ | Mr. Chanrattana |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 16 | 2.00 p.m. to 3.30 p.m. | អាហាររូបត្ថម្ភ | Dr. Sovathana |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |
| | 3.45 p.m. to 4.45 p.m. | អាហាររូបត្ថម្ភ (Continue) | Dr. Sovathana |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| Day- 9: ថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ២០១៧ | | | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី៨ | NCHADS Team |
| 19 | 8.30 a.m. to 9.45 a.m. | ការគ្រប់គ្រងវិបត្តិផ្លូវចិត្ត | Mr. Chanrattana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| | 10.00 a.m. to 12.00 p.m. | ការគ្រប់គ្រងវិបត្តិផ្លូវចិត្ត (Continue) | Mr. Chanrattana |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| 17 | 2.00 p.m. to 3.30 p.m. | ការប្រុងប្រយ័ត្នជាសកលនិងការព្យាបាលការពារក្រោយពីមានការប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារការចំលងរោគ | Dr. Chan Koung |
| | *3.30 p.m. to 3.45 p.m.* | *Tea Break* | |
| | 3.45 p.m. to 4.45 p.m. | ការប្រុងប្រយ័ត្នជាសកលនិងការព្យាបាលការពារក្រោយពីមានការប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារការចំលងរោគ (Continue). | Dr. Chan Koung |
| | 4.45 p.m. to 5.00 pm. | សង្ខេបប្រធានបទថ្ងៃនេះ | NCHADS Team |
| *Day- 10: ថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ២០១៧* | | | |
| | 8.00 a.m.to 8.30 a.m. | រំលឹកមេរៀនថ្ងៃទី៩ | NCHADS Team |
| 25 | 8.30 a.m. to 9.45 a.m. | Record maintenance and reporting | Mr. Chanrattana |
| | *9.45 .m. to 10.00 a.m.* | *Tea Break* | |
| | 10.00 a.m. to 12.00 p.m. | Record maintenance and reporting (Continue). | Mr. Chanrattana |
| | *12.00 p.m. to 2.00 p.m.* | *Lunch break* | |
| | 2.00 p.m. to 3.15p.m. | -តេស្តក្រោយវគ្គបណ្តុះបណ្តាល<br>-ការវាយតំលៃបញ្ចប់វគ្គបណ្តុះបណ្តាល | NCHADS Team |
| | *3.15 p.m. to 3.30 p.m.* | *Tea Break* | |

| | | | |
|---|---|---|---|
| | 3.30 p.m. to 4.00 p.m. | សង្ខេបប្រធានបទថ្ងៃទី១ ដល់ ថ្ងៃទី១០ | NCHADS Team |
| | 4.00 p.m. to 5.00 pm. | *ពិធីបិទវគ្គក្រោមអធិបតី:*<br>• សន្និដ្ឋាន<br>• មតិសំណេះសំណាល និងចូលរួមចែក វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាជូនដល់សិក្ខាកាម ក្នុងវគ្គបញ្ចប់របស់លោកប្រធានអង្គការ AHF.<br>• មតិសំណេះសំណាល ព្រមទាំងចែកវិញ្ញា បនប័ត្របញ្ជាក់ការសិក្សាជូនដល់សិក្ខាកាម និងការប្រកាសបិទរបស់លោកប្រធានមជ្ឈមណ្ឌលជាតិ (NCHADS). | NCHADS Team |

## សកម្មភាពនៃវគ្គបណ្តុះបណ្តាល:

- ថ្ងៃទី១ (០១ ខែឧសភា ២០១៧)

លោកវេជ្ជ. លី ពេញស៊ុន ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគមានមតិសំណេះសំណាលជូនដល់សិក្ខាកាមយ៉ាងច្រើន ព្រមទាំងមានអត្ថន័យល្អៗនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការថែទាំ-ព្យាបាលជំងឺឱកាសនិយមនិងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារនេះ ហើយមុននឹងប្រកាសបើកវគ្គលោកប្រធានក៏មានមតិ ផ្តាំផ្ញើថាសូមអស់លោក/លោកស្រី/អ្នកនាងកញ្ញាយកចិត្តទុកដាក់ និង ក្រេបជញ្ជក់នូវមេរៀនល្អៗ ពីគ្រូសម្របសម្រួលក្នុងរយៈពេលដប់ថ្ងៃនេះ ពីព្រោះ វគ្គបណ្តុះបណ្តាលគ្រូពេទ្យនេះខានមានប្រហែលជិតពីរឆ្នាំមកហើយ ឥឡូវទើបតែឆ្នាំ២០១៧ មានវគ្គបណ្តុះបណ្តាលនេះជាថ្មីម្តងទៀត ដូចនេះសូមអស់លោក/លោកស្រីប្រឹងប្រែងអោយអស់ពីសមត្ថភាពដើម្បីយកមេរៀន និងគោលការណែនាំថ្មីៗពីការផ្តល់ប្រឹក្សាស្តីពីការព្យាបាលជំងឺអេដស៍ទៅអនុវត្តនៅតាមសេវារៀងៗខ្លួន។ បន្ទាប់ពីការសំណេះសំណាលរួចមកក្រុមការងារផ្នែកថែទាំជំងឺអេដស៍គឺលោកស្រី លី ប៊ុណ្ណារី បានអោយសិក្ខាកាមធ្វើការណែនាំខ្លួនម្នាក់ម្តងៗ ដើម្បីអោយសិក្ខាកាមទាំងអស់បានស្គាល់ហើយព្រមទាំងបង្ហាញពីគោលបំណងនៃវគ្គបណ្តុះបណ្តាលជូនសិក្ខាកាមទាំងអស់បានដឹង បន្ទាប់មកចែកក្រដាសតេស្តអោយសិក្ខាកាមធ្វើតេស្តសាកល្បងមុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាលនេះ។ បន្ទាប់ពីនោះមកក្រុមការងារបានអោយសិក្ខាកាមសំរាកអាហារសំរន់ប្រហែល ១៥ នាទី ដើម្បីក្រុមការងារងាយស្រួលរៀបចំឯកសារមេរៀន និង LCD សំរាប់អោយគ្រូធ្វើការបង្ហាញមេរៀនដល់សិក្ខាកាម ។

ជាដំបូងការបង្ហាញមេរៀនរបស់គ្រូមកពីមជ្ឈមណ្ឌលជាតិស្តីពី Introduction to CoC និងមានការចូលរួមសំរបសំរួលដោយលោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ។ ជាបន្តការបង្ហាញរបស់លោកវេជ្ជស្រី. ខេង ម៉ាឆេត ***អំពីព័ត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជំងឺអេដស៍*** ដែលមានការចូលរួមសំរបសំរួលដោយលោកវេជ្ជ. ង៉ូវ បូរ៉ា។ បន្ទាប់ពីការបង្ហាញបានចប់លោកស្រី លី ប៊ុណ្ណារី បានធ្វើការសង្ខេបមេរៀនក្នុងរយៈពេលមួយថ្ងៃជូនសិក្ខាកាមបានដឹងទាំងអស់គ្នា។

- ថ្ងៃទី២ (០២ ខែឧសភា ២០១៧)

មុននឹងចូលដល់ការបង្ហាញមេរៀនជាបន្ត ក្រុមការងារផ្នែកថែទាំជំងឺអេដស៍ បានធ្វើការរំលឹកមេរៀននូវថ្ងៃទី ០១ គឺ ០១ ខែឧសភាឆ្នាំ២០១៧ ឡើងវិញ ដើម្បីធ្វើអោយសិក្ខាកាមកាន់ តែមានការចងចាំបន្ថែមទៀត ហើយ បន្ទាប់ពីនោះមក ទើបឈានដល់ការបង្ហាញមេរៀនជាបន្តបន្ទាប់៖

ការបង្ហាញរបស់លោកស្រីវេជ្ជ. ខេង ម៉ារេត ***អំពីព័ត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជំងឺអេដស៍*** ដែល មានការចូលរួមសំរបសំរួលដោយលោកវេជ្ជ. ង៉ូវ បូរ៉ា។

ការបង្ហាញរបស់លោកវេជ្ជ. ចាន់ គួង អំពី ***ការការពារការចម្លងមេរោគអេដស៍ក្រោយពេលផ្ទុកមេរោគអេដស៍*** ព្រមទាំងមានចូលរួមសំរបសំរួលដោយ លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ ក្នុងមេរៀននេះដែលលោក វេជ្ជបានបង្ហាញ អំពីវិធីផ្សេងៗ ការការពារការចម្លងមេរោគអេដស៍ក្រោយពេលផ្ទុកមេរោគអេដស៍ បន្ទាប់ពីបញ្ចប់ការបង្ហាញលោក វេជ្ជបានទុកឱកាសឲ្យសិក្ខាកាមសួរនូវចំនុចដែលមិនទាន់ច្បាស់ផងដែរ។

បន្ទាប់ពីសំរាកអាហារថ្ងៃត្រង់ លោកស្រីវេជ្ជ. ខេង ម៉ារេត បានធ្វើការបង្ហាញ ***អំពីការផ្តល់ប្រឹក្សាជាមូលដ្ឋាន ទាក់ទងមេរោគអេដស៍នឹងជំងឺអេដស៍*** ដែលមានការចូលរួមសំរបសំរួលដោយលោកវេជ្ជ. ង៉ូវ បូរ៉ា ដោយសារ មេរៀននេះមានរយៈពេលយូរ ក្រុមការងារបានឲ្យសិក្ខាកាមឈប់សំរាកពិសារអាហារសំរន់រយៈពេល១៥នាទី មុននឹងបន្តមេរៀននេះរហូតដល់ចប់។ ប៉ុន្តែមុននឹងបញ្ចប់មេរៀនក៏មានការសាកសួរសំនួរ និងការផ្តល់ចម្លើយពី លោកគ្រូ-អ្នកគ្រូសម្របសម្រួលដែរ។ បន្ទាប់ពីបញ្ចប់ការបង្ហាញក្រុមការងារនៃមជ្ឈមណ្ឌលជាតិ គឺលោកស្រី លី ប៊ុណ្ណារី បានធ្វើការសង្ខេបមេរៀនឡើងវិញ។

- ថ្ងៃទី៣ (០៣ ខែឧសភា ២០១៧)

មុននឹងចាប់ផ្តើមការបង្ហាញមេរៀន លោកស្រី លី ប៊ុណ្ណារី បានធ្វើការសាកសួររំលឹកមេរៀនដែលបានរៀននៅ ថ្ងៃទី ២ (០២ ខែឧសភា ឆ្នាំ២០១៧) ឡើងវិញដើម្បីអោយសិក្ខាកាមមានការចងចាំកាន់តែច្បាស់បន្ថែមទៀត មុននិងចូលមេរៀនថ្មី ។

បន្ទាប់ពីការរំលឹកមេរៀនត្រូវបានបញ្ចប់លោកស្រីវេជ្ជ. គី សុវឌ្ឍនា បានលើកយកមេរៀនមួយមកបង្ហាញស្តី ***អំពីការយល់ដឹងពីដំណាក់កាលវិវឌ្ឍន៍របស់កុមារ និងយុវវ័យ*** ក្នុងមេរៀននេះ លោកស្រីវេជ្ជ.បានឲ្យសិក្ខាកាម ចូលរួមយោលបល់ និង ចែករំលែកបទពិសោធន៍ទាក់ទងការផ្តល់ប្រឹក្សាទៅលើក្មេងនៅពេលពួកគេក្លាយជា មនុស្សពេញវ័យ តើពួកគេមានផលវិបាក រឺក៏ប្រែប្រួលអ្វីខ្លះ? ក្នុងនោះដែរសិក្ខាកាមបានចូលរួមជាមតិ យោលបល់ទាំងអស់គ្នា។ ក្រោយពីបញ្ចប់មេរៀន មានសិក្ខាកាមមួយចំនួនបានចោទជាសំនួរទៅកាន់អ្នកគ្រូថា :

***សំនួរ:*** តើក្មេងមានផ្ទុមមេរោគអេដស៍ និងមិនមានផ្ទុក មួយណាមានភាពវៃឆ្លាតជាង?

***ចំលើយ:*** លោកស្រីវេជ្ជ. គី សុវឌ្ឍនា បានផ្តល់ចំលើយថា ក្មេងដែលមិនមានជំងឺមានភាពវៃឆ្លាតជាង ម្យ៉ាងទៀត ក្មេងដែលផ្ទុកមេរោគអេដស៍ងាយនឹងកើតជំងឺផ្សេងទៀត។

***សំនួរ:*** តើរបៀបវាស់IQរបស់ក្មេងយ៉ាងណា?

***ចំលើយ:*** របៀបវាស់ IQ របស់ក្មេងមាន ៣ ដំណាក់កាល:

- សួរសំណួរឲ្យឆ្លើយ
- គូររូបភាព
- លេងហ្គេម

បន្ទាប់ពីបញ្ចប់ការបង្ហាញរបស់លោកស្រីវេជ្ជ. គី សុវឌ្ឍនា រួចមក លោក. ឡេង ចាន់រតនា បានធ្វើការ បង្ហាញនៅមេរៀន***អ្នកថែទាំតាមផ្ទះ:*** មេរៀននេះបានបង្ហាញពីការផ្តល់ប្រឹក្សាទៅលើអ្នកជំងឺនៅតាមសហគមន៍

ក៏ដូចជានៅតាមផ្ទះ ធ្វើយ៉ាងអោយពួកគាត់មានការយល់ដឹងពីសារៈសំខាន់នៃការលេបថ្នាំអោយបានទៀងទាត់ដើម្បីអោយសុខភាពរបស់ពួកគាត់មានភាពរឹងមាំ ជាពិសេសទៅទៀតបងប្អូនសាច់ញាតិរបស់អ្នកជំងឺត្រូវជួយផ្តល់ជាកំលាំងចិត្ត និងធ្វើយ៉ាងណាអោយអ្នកជំងឺមានភាពសប្បាយរីករាយ ព្រមទាំងជួយជំរុញអោយគាត់ចេះថែរក្សាសុខភាពអោយបានល្អ ហើយសំរាប់មេរៀននេះ លោកវេជ្ជ. ង៉ូវ បូរ៉ា ក៏បានចូលរួមជួយបន្ថែមនូវយោបល់ល្អៗ និងចែករំលែកបទពិសោធន៍ល្អៗមួយចំនួនដែលគាត់ធ្លាប់មានជូនដល់សិក្ខាកាមបានដឹងផងដែរ។

ក្រោយសំរាកអាហារថ្ងៃត្រង់ លោកវេជ្ជ. ចាន់ គួង បានធ្វើការបង្ហាញនូវមេរៀន ***តម្លៃនឹងអាកប្បកិរិយារបស់អ្នកផ្តល់ប្រឹក្សា*** ។ ក្នុងមេរៀននេះលោកវេជ្ជបណ្ឌិត បានបង្ហាញនៅភាពសំខាន់ៗរបស់អ្នកផ្តល់សេវាក្នុងការជួយអ្នកជំងឺ និងអាក្បកិរិយារបស់អ្នកផ្តល់ប្រឹក្សាគួរប្រព្រឹត្តក្នុងពេលផ្តល់ប្រឹក្សាដល់អ្នកជំងឺ។ បន្ទាប់ពីបញ្ចប់មេរៀន

បន្ទាប់មកលោកស្រីវេជ្ជ. ខេង ម៉ារេត បានបន្តបង្ហាញមេរៀន ***ការយកចិត្តទុកដាក់ថែទាំចំពោះអ្នកផ្តល់សេវា*** ក្នុងមេរៀននេះ គឺបានផ្តោតសំខាន់លើការចេះបន្ធូរអារម្មណ៍ និងវិធីកាត់បន្ថយស្រ្តេសនៅពេលអ្នកផ្តល់ប្រឹក្សាជួបប្រទះ។ នាពេលនោះដែលអ្នកគ្រូសម្របសម្រួលទាំងអស់បានឲ្យសិក្ខាកាមបង្ហាញនូវបទពិសោធន៏និងវិធីសាស្រ្តផ្សេងៗរបស់ខ្លួន ដែលពួកគាត់ធ្លាប់បានយកមកអនុវត្ត ដើម្បីកាត់បន្ថយភាពតានតឹងពេលពួកគាត់បានទទួលសម្ពាធពីអ្នកជំងឺ។ បន្ទាប់ពីការចែករំលែកលោកគ្រូអ្នកគ្រូសម្របសម្រួលក៏បានចែករំលែកនៅវិធីសាស្រ្តផ្សេងៗបន្ថែមទៀតក្នុងការកាត់បន្ថយស្រ្តេស។

បន្ទាប់ពីការបង្ហាញចប់របស់គ្រូនិមួយៗរួចមក លោកស្រី លី ប៊ុណ្ណារី បានធ្វើការសង្ខេបមេរៀនឡើងវិញដើម្បីអោយសិក្ខាកាមមានការចងចាំបន្ថែមទៀត។

- **ថ្ងៃទី៤** (០៤ ខែឧសភា ២០១៧)

ការបង្ហាញនៅមេរៀន ***ជំនាញក្នុងការធ្វើទំនាក់ទំនង*** ដែលធ្វើការបង្ហាញរបស់ លោកស្រីវេជ្ជ. គី សុវឌ្ឍនា សំរាប់មេរៀននេះមានការចូលរួមសំរបសំរួលដោយលោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ។

មុននឹងឈានដល់ការបង្ហាញមេរៀនបន្ត ក្រុមការងារបានឲ្យសិក្ខាកាមក្រោកឈរ និងលេងល្បែងថាមពលដែលមានការសម្របសម្រួលដោយ លោកស្រី លី ប៊ុណ្ណារី។ បន្ទាប់មកទៀតលោក ឡេង ចាន់រតនា បានធ្វើការបង្ហាញអំពី ***ការស្វែងយល់អំពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍*** ដែលមានការចូលរួមសម្របសម្រួលដោយលោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ។

- **ថ្ងៃទី៥** (០៥ ខែឧសភា ២០១៧)

មុននឹងឈានចូលដល់ការបង្ហាញមេរៀនជាបន្តក្រុមការងារផ្នែកថែទាំជំងឺអេដស៍បានធ្វើការរំលឹកនូវមេរៀនដែលបានរៀននៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ជាមុនសិន ក្នុងការរំលឹកនោះមានសិក្ខាកាមមួយចំនួនបានចូលរួមឆ្លើយនូវសំណួរជាច្រើនដែលអ្នកសំរបសំរួលយើងបានសួរទៅកាន់ពួកគាត់។ បន្ទាប់ពីការរំលឹក លោកស្រីវេជ្ជ. គី សុវឌ្ឍនា បានលើយកមេរៀន ***ការផ្តល់ប្រឹក្សាសម្រាប់បង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូន (PMTCT)*** ជូនដល់សិក្ខាកាម។ ក្រោយពីបញ្ចប់ការបង្ហាញមេរៀនក៏មានសំនួរសួរទៅកាន់អ្នកគ្រូភ្លាមៗទាក់ទងនឹងកាធ្វើតេស្ត ក្រោយបញ្ចប់ការសួរអ្នកគ្រូលោកគ្រូសម្របសម្រួលក៏បានចូលមកឆ្លើយសំនួរភ្លាមៗផងដែរ។ បន្ទាប់ពីនោះមក លោកស្រីវេជ្ជ. គី សុវឌ្ឍនា បានបន្តចូលទៅមេរៀនមួយទៀតដែលនិយាយអំពី ***ការពន្យារកំណើត*** មុននឹងចាប់ផ្តើមមេរៀននេះអ្នកគ្រូក៏បានចោទសួរសំនួរទៅកាន់សិក្ខាកាមថាហេតុអ្វីបានជាមានការបញ្ចូលមេរៀនការពន្យាកំណើតក្នុងកម្មវិធីជាតិ? ក្នុងពេលនោះសិក្ខាកាមបានចូលរួមឆ្លើយតបនិងសំនួរនោះវិញយ៉ាងក្បោះក្បាយផងដែរ។ ក្នុងមេរៀននេះ លោកស្រីវេជ្ជ.ក៏បានសង្កត់ធ្ងន់អំពីផលប្រយោជន៏នៃការពន្យារ

កំណើតជូនដល់សិក្ខាកាម និងវិធីក្នុងការពន្យារកំណើតផងដែរ។ មេរៀនទាំងពីរនេះក៏មានការសម្របសម្រួល និង ឆ្លើយសំនួរពីសំណាក់លោកវេជ្ជ. ង៉ូវ បូរ៉ា។

ក្នុងពេលរសៀលនេះ លោកស្រីវេជ្ជ. ខេង ម៉ារេត បានលើកបង្ហាញមេរៀន ***ជំងឺឱកាសនិយមនិងការបង្ការ*** ជូនដល់សិក្ខាកាម ដែលចូលរួមសំរបសំរួលដោយលោកវេជ្ជ. ង៉ូវ បូរ៉ា។ ក្នុងមេរៀននេះគឺបានសង្កត់ធ្ងន់លើជំងឺឱកាសនិយមដែលតែងតែកើតមានញឹកញាប់ចំពោះអ្នកជំងឺអេដស៍ និង វិធីបង្ការផងដែរ។ ក្រោយបញ្ចប់ការបង្ហាញក៏មានសំនួរពីសិក្ខាកាមដូចជាៈ

***សំនួរៈ*** ករណីអ្នកជំងឺអេដស៍ថ្មីមានជំងឺOI តើគួរចាប់ផ្តើមព្យាបាលពួកគាត់ពេលណា?

***ចំលើយៈ*** ចាប់ផ្តើមព្យាបាលឲ្យបានឆាប់រហ័យក្រោយពេលព្យាបាលOIចប់

***សំនួរៈ*** ក្នុងករណីអ្នកជំងឺថ្មី ប៉ុន្តែមិនមានជំងឺOIទេ តើគួរចាប់ផ្តើមព្យាបាលពេលណា?

***ចំលើយៈ*** ជាទូទៅការព្យាបាលត្រូវធ្វើឲ្យបានឆាប់រហ័យកាន់តែល្អ ប៉ុន្តែជាទូទៅក្នុងអំឡុងពេល២សប្តាហ៍ដោយសារយើងត្រូវពិនិត្យរកOI និងផ្តល់ប្រឹក្សាអំពីពត៍មានទាក់ទងជំងឺអេដស៍ជូនគាត់។

បន្ទាប់ពីការបង្ហាញរបស់គ្រូនិមួយៗត្រូវបានបញ្ចប់រួចមកលោកស្រី លី ប៊ុណ្ណារី បានធ្វើការសង្ខេបមេរៀនក្នុងថ្ងៃទី៥នេះជូនសិក្ខាកាមបានដឹងកាន់ច្បាស់បន្ថែមទៀត។

- ថ្ងៃទី៦ (០៨ ខែឧសភា ២០១៧)

លោកវេជ្ជ. ចាន់ គួង បានធ្វើរំលឹកនូវមេរៀនដែលបានរៀនៅថ្ងៃទី០៥ ខែ ឧសភា ២០១៧ បន្ទាប់មកទៀត លោកវេជ្ជ.បានបង្ហាញពី***ការប្រកាន់ខ្ជាប់ខ្ជួន(ការលេបថ្នាំត្រឹមត្រូវទៀងទាត់ និងតាមវេជ្ជបញ្ជា)ក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍*** រយៈពេលមួយព្រឹកពេញដោយមានការចូលរួមសម្របសម្រួលនិងឆ្លើយសំនួរពីសំណាក់លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ។

នាវេលាម៉ោង២.០០នាទី លោកស្រីវេជ្ជ. គី សុវឌ្ឍនា បានលើកមេរៀន ***អន្តរកាលនៅក្នុងវ័យជំទង់*** មកបង្ហាញ នៅក្នុងមេរៀននេះលោកស្រីវេជ្ជបានបង្ហាញនៅភាពផ្លាស់ប្តូរនៅរូបរាងកាយក៏ដូចជាផ្លូវចិត្តរបស់មនុស្សជូនដល់សិក្ខាកាមអោយបានយល់ដឹងបន្ថែម ដើម្បីងាយស្រួលផ្តល់ប្រឹក្សាទៅអ្នកជំងឺ។ សំរាប់មេរៀននេះលោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ ចូលរួមបន្ថែម និងចែករំលែកបទពិសោធន៍ទាក់ទងនឹងមេរៀននេះជូនដល់សិក្ខាកាមទាំងអស់បានដឹង។ បន្ទាប់មកលោកស្រីវេជ្ជ. គី សុវឌ្ឍនា ក៏បានលើកមេរៀន***ភាពអស់កំលាំងចិត្តកម្លាំងកាយរបស់អ្នកថែទាំ*** មកបង្ហាញជាបន្តទៀត ហើយចំណែកសិក្ខាកាមហាក់មានការចាប់អារម្មណ៍ក្នុងមេរៀននេះដោយសារពួកគាត់តែជួបប្រទះនូវហេតុការបែបនេះ។ ម្យ៉ាងទៀតសិក្ខាកាមក៏បានចែករំលែកនៅហេតុផលដែលពួកគាត់អស់កម្លាំងក្នុងការផ្តល់ប្រឹក្សា និងបានចោទសួរជាច្រើនផងដែរ។

- ថ្ងៃទី៧ (០៩ ខែឧសភា ២០១៧)

បន្ទាប់ពីការរំលឹកទៅលោក ឡេង ចាន់រតនា បានបង្ហាញនូវមេរៀន ***ការផ្លាស់ប្តូរឥរិយាបទក្នុងការទំនាក់ទំនង*** ក្នុងមេរៀននេះពិតជាមានសារៈសំខាន់ដោយសារ បានបង្ហាញពីពេលវេលាដែលគួរផ្លាស់ប្តូរឥរិយាបទក្នុងការប្រឹក្សានៅពេលការផ្តល់ប្រឹក្សាមិនមានប្រសិទ្ធភាព និងបានបង្ហាញពីវិធីសាស្រ្តក្នុងការផ្លាស់ប្តូរ។ ម្យ៉ាងទៀតការផ្លាស់ប្តូរឥរិយាបទក្នុងការទំនាក់ទំនងដែលមានសារៈសំខាន់ក្នុងការព្យាបាលអ្នកជំងឺអេដស៍។

នាពេលរសៀលនេះ លោកស្រីវេជ្ជ. គី សុវឌ្ឍនា ក៏បានបង្ហាញនៅមេរៀន***ការថែទាំ និងព្យាបាលបន្ថយការឈឺចាប់បណ្តោះអាសន្ន*** ជូនដល់សិក្ខាកាម សំរាប់មេរៀននេះសិក្ខាកាមមានការចាប់អារម្មណ៍ និងមានសំនួរជា

ច្រើនបានចោទសួរ ហើយជាមួយគ្នានោះ លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ បានចូលរួមឆ្លើយតបវិញភ្លាមៗទៅនឹងសំណួររបស់សិក្ខាកាមដែលបានសួរ។

- ថ្ងៃទី៨ (១០ ខែខូសតា ២០១៧)

នាវេលាព្រឹកថ្ងៃទី១០នេះ លោកស្រី លី ប៊ុណ្ណារី បានចូលរួមធ្វើការសាកសួររំលឹកមេរៀនបន្ថែមទៀតជូនដល់សិក្ខាកាម។ ជាបន្តទៀត លោក ឡេង ចាន់រតនា ក៏បានបន្តការការបង្ហាញមេរៀន ***ការបង្ហើបការពិតពីស្ថានភាពមេរោគអេដស៍ដល់កុមារ*** ក្នុងមេរៀននេះ លោក បានធ្វើការសាកសួរថា តើអាយុប៉ុន្មានដែលគួរប្រាប់ការពិតជូនដល់កុមារ? ក្រោយពីបានស្តាប់សំនួរ សិក្ខាកាមបានចូលរួមឆ្លើយចម្លើយផ្សេងៗគ្នា។ ជាចុងបញ្ចប់លោក ក៏បានប្រាប់ពីចម្លើយត្រឹមត្រូវ ហើយគ្រានោះលោកវេជ្ជ. ង៉ូវ បូរ៉ា បានចូលរួមប្រាប់ហេតុផលដែលគួរប្រាប់ក្មេងនៅអាយុប៉ុណ្ណឹងផងដែរ។

លោកស្រីវេជ្ជ.គី សុវឌ្ឍនា បានធ្វើការបង្ហាញនៅមេរៀនថ្មីមួយទៀត ***គឺ អាហាររូបត្ថម្ភ*** មេរៀននោះពិតជាមានសារៈសំខាន់ណាស់ ដោយសារជាទូរទៅក្មេងដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍តែងតែមានសុខភាពទន់ខ្សោយ និងមានភាពខ្វះខាតក្នុងការហូបចុក ហើយសំរាប់មេរៀននេះលោកស្រីវេជ្ជ. បានធ្វើបង្ហាញបន្ថែមពីសារៈប្រយោជន៏របស់អាហាររូបត្ថម្ភចំពោះក្មេង។

- ថ្ងៃទី៩ (១១ ខែខូសតា ២០១៧)

លោក ឡេង ចាន់រតនា បានបង្ហាញពី***ការគ្រប់គ្រងវិបត្តិផ្លូវចិត្ត*** ក្នុងមេរៀននេះលោកក៏បានបង្ហាញនៅវិធីល្អៗក្នុងការគ្រប់គ្រងកំហឹង និងការកាត់បន្ថយសម្ពាធជាដើម។ មុនពេលសំរាកអាហារសម្រន់ ក្រុមការងារថែទាំងជំងឺអេដស៍បានឲ្យសិក្ខាកាមអនុវត្តន៏នៅវិធីដែលលោកទើបតែបង្រៀនភ្លាមៗ ដោយឲ្យសិក្ខាកាមក្រោកឈរហើយបិទភ្នែកតាំងសមាធិរយៈពេល៥នាទី ដោយសារវាជាវិធីដ៏ល្អក្នុងការគ្រប់គ្រងវិបត្តិផ្លូវចិត្តផងដែរ។ ក្រោយពីសម្រាកលោកក៏បានបន្ត និងបញ្ចប់មេរៀននេះ ហើយគ្រូសម្របសម្រួលទាំងអស់ក៏បានចូលរួមចែករំលែកនៅវិធីក្នុងការគ្រប់គ្រងវិបត្តិផ្លូវចិត្ត។

នាពេលរសៀលនេះលោកវេជ្ជ. ចាន់ គួង បានលើកយកមេរៀន ***ការប្រុងប្រយ័ត្នជាសកលនិងការព្យាបាលការពារក្រោយពីមានការប្រឈមមុខគ្រោះថ្នាក់ដោយសារការចម្លងជាត*** មេរៀននេះពិតជាមានសារៈសំខាន់ដោយសារអ្នកផ្តល់ប្រឹក្សាងាយនឹងមានការឆ្លងរោគពីអ្នកជំងឺ ដូច្នេះអ្នកផ្តល់ប្រឹក្សាត្រូវយល់ច្បាស់នៅវិធីការពារនិងការជួយព្យាបាលពេលមានការប៉ះពាល់នឹងមេរោគ។ ក្រោយបញ្ចប់សិក្ខាកាមមានការសួរសំនួរមួយចំនួនដូចជា:

***សំនួរ:*** តើថ្នាំPEP អាចរកយកថ្នាំនេះនៅទីណាខ្លះ?

***ចំលើយ:*** ថ្នាំនេះយើងអាចរកបាននៅគ្រប់ទីកន្លែងដែលមានសេវាថែទាំជំងឺអេដស៍

***សំនួរ:*** ក្នុងករណីមានអ្នករងគ្រោះដោយចៃដន្យនៅពេលយប់រឺនៅចុងសប្តាហ៏តើគួរយកថ្នាំនៅឯណា?

***ចំលើយ:*** ក្នុងករណីនេះនៅគ្រប់មន្ទីរពេទ្យតែងមានអ្នកនៅទីនោះរយៈពេល២៤ម៉ោងនិងរៀងរាល់ថ្ងៃផងដែរ។

***សំនួរ:*** តើថ្នាំនេះមានប្រសិទ្ធភាពល្អពេលណា?ហើយការព្យាបាលមានរយៈពេលប៉ុន្មាន?

***ចំលើយ:*** ទាក់ទងនិងការប្រើប្រាស់ថ្នាំនេះគឺមានរយៈពេល២៨ថ្ងៃ ហើយប្រសិទ្ធភាពដែលល្អបំផុតគឺ៤ម៉ោងក្រោយការប្រឈម ហើយវានឹងមានប្រសិទ្ធភាពមិនសូវល្អក្រោយ៧២ម៉ោង។

- ថ្ងៃទី១០ (១២ ខែខូសតា ២០១៧)

លោក ជា ចំណាន បានបង្ហាញអំពី *Record Maintenance and Reporting* សំរាប់មេរៀននេះលោកបានពន្យល់ទៅសិក្ខាកាមយ៉ាងក្បោះក្បាយព្រមទាំងបានសួរបញ្ជាក់ទៅសិក្ខាកាមថាបានយល់ច្បាស់ហើយឬនៅជាពិសេសគឺទំរង់របាយការណ៍កត់ត្រាពីអ្នកជំងឺ ព្រោះខ្លាចគ្រូបំពេញមិនគ្រប់លក្ខណៈដូចនេះហើយទើបធ្វើអោយលោកប្រើពេលពេញមួយព្រឹកទើបបញ្ចប់មេរៀនមួយនេះ។

ការបង្ហាញមេរៀនត្រូវបានបញ្ចប់ក្នុងរយៈពេលពីរសប្តាហ៍នេះ បន្ទាប់មកទៀតក្រុមការងារផ្នែកថែទាំជំងឺអេដស៍ បានធ្វើការសង្ខេបមេរៀនថ្ងៃទី០១ដល់ទី១០ ជូនដល់សិក្ខាកាមទាំងអស់ឡើងវិញ។ ហើយបន្ទាប់មកបានធ្វើការចែកក្រដាសតេស្តសាកល្បងក្រោយវគ្គជូនដល់សិក្ខាកាម ដើម្បីចង់ដឹងសមត្ថភាពរបស់សិក្ខាកាមបន្ទាប់ពីទទួលការបណ្តុះបណ្តាលក្នុងកំឡុងពេលរយៈពេលពីរសប្តាហ៍នេះ។

បន្ទាប់ពីធ្វើតេស្តចប់ ក្រុមការងារផ្នែកថែទាំជំងឺអេដស៍ បានធ្វើការបង្ហាញជាសង្ខេបគ្រប់មេរៀន និងបង្ហាញពីលទ្ធផលតេស្តសាកល្បងមុនពេលរៀន និងក្រោយពេលរៀន ជូនដល់សិក្ខាកាមទាំងអស់បានដឹង និងធ្វើការដំណោះស្រាយរាល់បញ្ហារបស់សិក្ខាកាមដែលបានលើកឡើងក្នុងពេលវគ្គចំនួន១០ ថ្ងៃនេះ។

៧. លទ្ធផលតេស្តសាកល្បងមុន និងក្រោយពេលរៀនៈ

| | | | | | |
|---|---|---|---|---|---|
| តេស្តសាកល្បង | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ | សរុប |
| | *១២ នាក់* | *០៨ នាក់* | *០៤ នាក់* | *០២នាក់* | *២៦ នាក់* |
| តេស្តក្រោយសាកល្បង | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ | សរុប |
| | *២៤ នាក់* | *០១នាក់* | *០ នាក់* | *០១នាក់* | *២៦នាក់* |

៨. ការវាយតំលៃនៃវគ្គសិក្សា

| | វែងពេក | សមរម្យ | ខ្លី | ខ្លីពេក |
|---|---|---|---|---|
| ▪ **រយៈពេលបណ្តុះបណ្តាល** | ២២ | ០៤ | ០ | ០ |
| | ល្អណាស់ | ល្អ | មធ្យម | ខ្វះខាត |
| ▪ **ទីកន្លែង** | ០៦ | ១២ | ០៨ | ០ |
| ▪ **ការរៀបចំ** | ២០ | ០៦ | ០ | ០ |
| ▪ **ឯកសារ និងសំភារៈក្នុងវគ្គបណ្តុះបណ្តាល** | ១២ | ១៤ | ០ | ០ |
| | បានទាំងស្រុង | ភាគច្រើន | បានខ្លះៗ | គ្មាន |
| ▪ **តើវគ្គបណ្តុះបណ្តាលនេះឆ្លើយតបទៅនឹងគោលបំណងរបស់វគ្គកំរិតណា?** | ២៦ | ០ | ០ | ០ |
| | សំខាន់ណាស់ | មិនសូវសំខាន់ | គ្មានសំខាន់ | |
| ▪ **តើវគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់ កំរិតណាក្នុងការងាររបស់អ្នក?** | ២៦ | ០ | ០ | |

- ការផ្តល់យោបល់ទៅលើវគ្គបណ្តុះបណ្តាលវគ្គ:
    - គ្រូសំរបសំរួលពន្យល់បានក្បោះក្បាយល្អ
    - ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់សំរាប់ការងាររបស់អ្នកផ្តល់ប្រឹក្សា
    - មេរៀនមួយចំនួនមានការបង្កើតថ្មី និងមានការបន្ថែមទៅលើមេរៀនចាស់មួយចំនួន
    - បានទទួលចំណេះដឹងថ្មីបន្ថែមពីគ្រូសំរបសំរួល
- ចំណុចខ្វះខាតក្នុងវគ្គបណ្តុះបណ្តាល:
    - ទីកន្លែងរៀនឆ្ងាយ
    - បន្ទប់រៀនរាងតូចចង្អៀត
- សំណូមពរ:
    - សុំកន្លែងឲ្យមានភាពល្អប្រសើរជាងនេះ ដោយសារ បន្ទប់ប្រជុំតូចចង្អៀត និងបន្ទប់ទឹកនៅឆ្ងាយ ម្យ៉ាងទៀតទាក់ទងនឹងអាហារសំរន់គឺអាហារដដែលស្ទើររយៈពេល១០ថ្ងៃ។
    - សុំឱ្យមានវគ្គបណ្តុះបណ្តាលដល់គ្រូពេទ្យថ្មីៗបន្ថែមទៀត ពីព្រោះនៅតាមមន្ទីរពេទ្យមួយចំនួននៅមានការខ្វះខាត ព្រោះគ្រូពេទ្យចាស់ៗមួយចំនួនបានចូលនិវត្តន៍។
    - បន្ទាប់ពីវគ្គបណ្តុះបណ្តាលរួចមកសុំឱ្យមានវគ្គរំលឹកបន្តទៀត។

៩. សេចក្តីសន្និដ្ឋាន:

វគ្គបណ្តុះបណ្តាលនេះបានបញ្ចប់ដោយជោគជ័យក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកវេជ្ជ***លី ពេញ ស៊ុន*** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ និងលោកវេជ្ជ. ស្រី វណ្ណធួន ប្រធានអង្គការ AHF លោកទាំងពីរបានធ្វើការផ្តាំផ្ញើដល់សិក្ខាកាមដែលបានចូលរួមឱ្យយកចំណេះដឹងថ្មីៗទាំងនេះទៅអនុវត្តនៅកន្លែងផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍នៅតាមមន្ទីរពេទ្យប្រកបដោយគុណភាពខ្ពស់ និងប្រកាសបិទវគ្គបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សា ស្តីពីការផ្តល់ប្រឹក្សាលើការថែទាំ និង ព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារផ្ទុកមេរោគអេដស៍ ចាប់ពីពេលនេះតទៅ មុននឹងបញ្ចប់ក្រុមការងារផ្នែកថែទាំជំងឺអេដស៍មានកិត្តិយសសូមគោរពអញ្ជើញប្រធានមជ្ឈមណ្ឌលជាតិ និងលោកប្រធានអង្គការ AHF ចូលរួមចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនដល់សិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ។

| | |
|---|---|
| បានឃើញ និងឯកភាព | ភ្នំពេញ,ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ |
| ប្រធានមជ្ឈមណ្ឌលជាតិ | អ្នកធ្វើរបាយការណ៍ |
| វេជ្ជ.លី_ពេញ ស៊ុន | លី ប៊ុណ្ណារី |